ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៧៥ រប-៩៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោក ប្រធានតុលាការកំពូល
លោក អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
លោក ប្រធានសាលាឧទ្ធរណ៍
លោក ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
លោក ប្រធានតុលាការគ្រប់ខេត្ត ក្រុង
លោក ព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** ការឆ្លើយតបនិងសារព័ត៌មានដែលចុះផ្សាយអត្ថបទពាក់ពន្ធ័និងការងាររបស់តុលាការ ។

ខ្ញុំសូមជម្រាបអស់លោកជ្រាបថា សព្វថ្ងៃនេះមតិសាធារណៈជាពិសេសសារព័ត៌មានមិនពេញចិត្តនិងការងាររបស់តុលាការ អយ្យការទេ ហើយសរសេរទិទៀនជាញឹកញយ ។

យើងត្រូវទទួលស្គាល់ថាការមិនពេញចិត្តបណ្តាលមកពីការមិនយល់របស់គេ ចំពោះហេតុផលដែលនាំឱ្យតុលាការសម្រេចយ៉ាងនេះឬយ៉ាងនោះ ជាពិសេសភាគច្រើនគេរៀបរាប់តាមការរាយការណ៍ របស់តែភាគីម្ខាងពោលគឺប្រាស់ចាកការពិតក្នុងសំណុំរឿង ហើយរហូតដល់មានការបង្ខូចកិត្តិយសតុលាការទៀតផង ។

ដើម្បីបំភ្លឺមតិសាធារណៈ ការពារកិត្តិយសរបស់អស់លោកនិងកិត្តិនាមរបស់តុលាការ អយ្យការ ខ្ញុំសូមអស់លោកសរសេរទៅពន្យល់គេវិញ នៅពេលដែលមានអត្ថបទប៉ះពាល់ដល់អស់លោក ឬដល់តុលាកា សុំឱ្យគេចុះផ្សាយអំពីការពិតតាមសេចក្តីបំភ្លឺរបស់យើង ដោយប្រើពាក្យសំដីអព្យាក្រិត្យ កុំឱ្យមានរឿងជាមួយអ្នកសារព័ត៌មានឱ្យសោះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្នួន**